# ចិញ្ចឹមអង្ក្រងយកពងលក់

អង្ក្រងត្រូវបានគេប្រើប្រាស់ធ្វើជាគ្រឿងកំចាត់សត្វល្អិតចេញពីដំណាំ អស់កាលជាច្រើនពាន់ឆ្នាំមកហើយ នៅក្នុងប្រទេសចិន។ ដោយបង្កើតឲ្យមានសំបុកអង្ក្រងនៅតាមដើមឈើយកផ្លែ តាមរយៈការចងខ្សែបន្តពីដើមឈើមួយទៅដើមឈើមួយទៀតសម្រាប់ឲ្យអង្ក្រងវាបង្កើតសំបុកថ្មីនៅលើដើមឈើថ្មី។



ក្រៅពីត្រូវបានប្រើធ្វើជាគ្រឿងកំចាត់សត្វល្អិតក្នុងចំការដំណាំលាងអង្ក្រង គឺជាអាហារពិសេសម្យ៉ាងមានឱជារសយ៉ាងឆ្ងាញ់ពិសារ ត្រូវបានពលរដ្ឋនៅក្នុងតំបន់ត្រូពិកនិយមចូលចិត្ត សូម្បីនៅក្នុងប្រទេសកម្ពុជាយើងក៏ដោយ។

ពងអង្ក្រងនៅក្នុងទីផ្សារសព្វថ្ងៃ ពងអង្ក្រងថ្មី មានតម្លៃរហូតដល់មួយគីឡូជាងមួយម៉ឺនរៀល។ ឯពងអង្ក្រងជ្រក់រួច មានតម្លៃច្រើនជាងនេះ។

សូមយកទៅពិចារណាចុះថា តើវាអាចឲ្យយើងរកចំណូលបានដែរឬទេ? បើសិនជាមួយថ្ងៃអាចរកពងបានទៅដប់គូឡូ..!!

ដើម្បីចិញ្ចឹមអង្ក្រងយកពង គឺជារឿងមួយងាយស្រួលបំផុត ទោះបីមានចំការខ្លួនឯងក្ដី គ្មានក្ដីមិនមែនជាបញ្ហាឡើយ ព្រោះនៅតាមព្រៃជាយៗភូមិតែងមានដើមឈើមានសម្បុកអង្ក្រងនៅទីនោះស្រាប់ បើនៅតាមចំការតែងមានដើមស្វាយ ឬដើមឈើផ្សេងៗ យើងគ្រាន់តែយកខ្សែមកចងពីដើមឈើមួយទៅដើមឈើមួយទៀត គឺជាការស្រេច។

ចំពោះចំណីរបស់វាវិញ យើងអាចយកកាកសំណល់ត្រីសាច់ពីផ្ទះបាយដាក់លើអ្វីមួយ ទៅចងព្យួរលើដើមឈើឲ្យបានច្រើនដើម នោះការពង្រីកសម្បុករបស់វាក៏មានច្រើនតាមនោះដែរ។

បើដើមឈើណាគ្មានអង្ក្រងចូលយកចំណីទៅដាក់ព្យួរនៅលើដើមឈើនោះ រួចយកសំបុកអង្ក្រងមួយទៅដាក់ត្រង់ទីដែលបានដាក់ចំណីនោះ វានឹងបង្កើតសំបុកនៅលើដើមឈើនោះមិនខាន។

យើងអាចដាក់ចំណីរាល់ថ្ងៃ ឬរៀងរាល់៥ថ្ងៃម្តងក៏បាន ដោយចងចំណីនៅលើខ្សែ ដែលបានចងបន្ត ពីដើមមួយទៅដើមឈើមួយទៀត។

អង្ក្រងវាបង្កើតពងលឿនណាស់ ក្នុងមួយសំបុកជួនកាលអាចប្រមូលពងបានរហូតមួយគីឡូក្រាមក៏មាន ក្នុងរង្វង់ ២០ថ្ងៃម្តង។ ការផ្តល់ចំណីឲ្យបានទៀងទាត់ធ្វើឲ្យវាពង្រីកសំបុកបានលឿន និងបង្កើតសំបុកថ្មីក៏ច្រើនដែរ។

ការយកពងអង្ក្រងមិនចាំបាច់បំផ្លាញសំបុកវាទាំងមូលឡើយ គឺទុកពីក្រោមសំបុក យកតែពងវាបានហើយ។

ពងអង្ក្រងដែលយកបាន អាចលក់ឲ្យគេឆៅ ឬជ្រក់លក់ខ្លួនឯងក៏បាន វាអាចជាការរកចំណូលមួយជាបន្ថែមក្រោយពីទំនេរពីការងារធម្មតា៕



(ដកស្រង់ចេញពី ខេមបូឌាអេចប្រេសញូស៍)